# យុត្តាធិការ (jurisdiction)

យុត្តាធិការ ជាអំណាចរបស់រដ្ឋក្នុងការចែងនិងដាក់ទោសអំពើល្មើសអនុវត្តច្បាប់ និងវិនិច្ឆ័យសេចក្តីលើអំពើល្មើស។ យុត្តាធិការមានក្នុងស្រុក ឬមានសម្រាប់សកម្មភាពល្មើសក្រៅប្រទេស (extraterritorial jurisdiction)។

រដ្ឋ កំណត់យុត្តាធិការក្នុងច្បាប់ដោយផ្អែកលើគោលការណ៍ចំនួន ៤៖ ១. ដែនដីដែលសំដៅលើទីកន្លែងដែលអំពើល្មើសកើតមាន ដែលចែកជាពីរ គឺធាតុផ្សំនៃបទល្មើសបានកើតមានឡើង (subjective territoriality) និងទីកន្លែងដែលផលវិបាកនៃបទល្មើសកើតមានឡើង (objective territoriality)។ ២. បុគ្គលមានសញ្ជាតិរបស់ខ្លួនដែលប្រព្រឹត្ត ដែលអាចកើតមាននៅក្រៅដែនដី (active nationality) ឬ ជនរងគ្រោះនៃអំពើជាប្រជាជននៃរដ្ឋនោះ (passive nationality)។ ៣. គោលការណ៍ការពារប្រយោជន៍ (protective principle) ដែលតាមនេះ រដ្ឋមានសមត្ថកិច្ចលើបទល្មើសប្រព្រឹត្តនៅទីណាដោយជនបរទេស ដែលប៉ះពាល់ដល់សន្តិសុខ ឬអធិបតេយ្យភាពរបស់រដ្ឋ និងទី ៤. គោលការណ៍សកល (universality theory) បង្កើតជាយុត្តាធិការ លើបទឧក្រិដ្ឋកម្មធ្ងន់ធ្ងរក្រោមច្បាប់អន្តរជាតិ ដូចជាប្រល័យពូជសាសន៍ (genocide)។

ធាតុចេញក្រៅប្រទេសនៃយុត្តាធិការ ដូចបង្ហាញខាងលើ អាចបង្កការលំបាក ប៉ះដល់អធិបតេយ្យភាពរបស់រដ្ឋដទៃ ជាពិសេស ការកាន់តែពង្រីកដែនយុត្តាធិការលើបទល្មើសច្រើនប្រភេទ កើតមាននៅក្រៅប្រទេស ធ្វើឲ្យប៉ះប្រយោជន៍រដ្ឋឬបុគ្គលបរទេសទាំងនោះ។ ជាក់ស្តែង សហរដ្ឋអាមេរិក បានពង្រីកយុត្តាធិការក្រៅដែនដី លើបទល្មើសជាច្រើន ដូចជា ភេរវកម្ម គ្រឿងញៀន ការរត់ពន្ធមនុស្ស ការលាងសម្អាតប្រាក់ជាដើម។

ជាក់ស្តែងឆ្នាំ ១៩៩៥ ប្រធានាធិបតី Bill Clinton បានចេញបទបញ្ជាដាក់ទណ្ឌកម្មករណីចំនួន ៤២ ក្រោមច្បាប់ស្តីពី International Emergency Economic Power Acts (IEEPA) ដោយបង្កកទ្រព្យសម្បត្តិមេដឹកនាំ នៃក្រុមហ៊ុនជួញដូរគ្រឿងញៀនក្នុងប្រទេសកូឡុំប៊ី។

ក្រៅពីយុត្តាធិការស៊ីវិល ក៏មានយុត្តាធិការយោធា (courts-martial jurisdiction) ហើយនាពេលខ្លះ មានការអះអាងអំពីការជាន់សមត្ថកិច្ច។ វាទាមទារឲ្យមានភស្តុតាងកម្រិតហួសពីវិមតិ សង្ស័យថា ថាតុលាការណាមួយមានសមត្ថកិច្ច ក្នុងករណីមានទំនាស់សមត្ថកិច្ច (Joshua Dressler, Encyclopedia of Crime and Justice, 2nd Ed., 2002, pp. 861-864)។